រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# *សេចក្តីប្រកាសពត៌មាន*

*សំរាប់ការផ្សាយចេញបន្ទាន់*

*ថ្ងៃអង្គារ៍ ទី២១ ខែតុលា ឆ្នាំ២០១៤*

## របាយការណ៍តម្លាភាពទី៣ បង្ហាញពីការធ្វើឲ្យប្រសើរក្នុងលក្ខខណ្ឌការងារ

ភ្នំពេញ, ប្រទេសកម្ពុជា៖ គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជានៃអង្គការអន្តរជាតិខាងការងារនៅថ្ងៃនេះ បានចេញផ្សាយរបាយការណ៍តម្លាភាពលើកទី៣ ដែលគិតចាប់ពីខែកក្កដា ដល់ខែកញ្ញាឆ្នាំ ២០១៤។ របាយការណ៍នេះ ឆ្លុះបញ្ចាំងពីលក្ខខណ្ឌការងារ របស់រោងចក្រកាត់ដេរចំនួន ២៩៨រោងចក្រនៅកម្ពុជា។

រោងចក្រ២ក្នុងចំណោមរោងចក្រទាំង១៣ រួមទាំងក្នុងក្រុមការអនុវត្តច្បាប់នៅមានកម្រិតទាប បានធ្វើការផ្ទៀងផ្ទាត់កែលម្អចំនុចចំនួន៣១ ហើយជាលទ្ធផល រោងចក្រទាំង២នោះ ត្រូវបានដកចេញពីតារាងនៃការអនុវត្តច្បាប់មានកម្រិតទាប។ រោងចក្រដែលនៅក្នុងក្រុមការអនុវត្តច្បាប់នៅមានកម្រិតទាប សំដៅលើរោងចក្រដែលធ្លាក់ក្រោមមធ្យមភាគភាគនៃការអនុវត្តច្បាប់ (two standard deviations) ក្នុងការអនុលោមលើចំនុចចំនួន៥២ ក្នុងចំណោមរោងចក្រដែលត្រូវបានត្រួតពិនិត្យបីដង ឬ លើសពីបីដង ដោយគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា។

រោងចក្រចំនួនមួយភាគបួន នៃរោងចក្រចំនួន៩៥ ដែលត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍ស្តីពីបញ្ហាចំបងៗ បានធ្វើការកែលម្អលើចំនុចទាំង២១ ក្នុងការប្រមើលទុកជាមុនថា ពួកគេនឹងត្រូវបានដាក់បញ្ចូលទៅក្នុងការរបាយការណ៍តម្លាភាពនេះ។ ចំនួនសរុបនៃការរំលោភបំពានលើបញ្ហាចំបងៗ នៅក្នុងក្រុមរោងចក្រនេះ បានធ្លាក់ចុះពី១០៩ ទៅ៧៥ចំនុច រវាងខែកក្កដា និងខែកញ្ញា ដែលស្មើនឹង៣០ភាគរយនៃការកែលម្អ។

រោងចក្រចំនួន៣៨ (ស្មើនឹង៤០ភាគរយនៃរោងចក្រដែលត្រូវបានបន្ថែមថ្មី) បានគោរពពេញលេញ លើច្បាប់ជាមូលដ្ឋាន ចំនួន២១ចំនុច រួមទាំងក្នុងប្រភេទបញ្ហាចំបងៗផងដែរ។ រោងចក្រចំនួន១២ទៀត ដែលបានធ្វើការកែលម្អ រវាងខែកក្កដា និងកញ្ញា ឆ្នាំ២០១៤ អាចចូលទៅក្នុងក្រុមរោងចក្រ ដែលគោរពបានទាំង២១ចំនុចនេះ ដែលមានចំនួនសរុប ៥០រោងចក្រ ស្មើនឹង៥២ភាគរយ ដោយមិនមានការរំលោភបំពានលើចំនុចក្នុងក្រុមបញ្ហាចំបងៗ។

ទិន្នន័យនៃការអនុវត្តទាំងឡាយខាងក្រោម ដែលចាប់តាំងពីមុនរបាយការណ៍តម្លាភាព និងក្រោយរបាយការណ៍តម្លាភាព បានបង្ហាញពីឥទ្ធិពលនៃរបាយការណ៍តម្លាភាពស្តីពីលក្ខខណ្ឌការងារ និងសិទ្ធិរបស់កម្មករនិយោជិត៖

- ការហ្វឹកហាត់ជម្លៀសចេញពីអាគារពេលមានអាសន្នកើនឡើងពី ៥៧% ដល់៧៦%

- រោងចក្ររើសអើងកម្មករនិយោជិត មានការថយចុះ ពី១៥% ទៅ ៧%
- រោងចក្រផ្តល់ប្រាក់រង្វាន់បន្ថែមអតីតភាពការងារត្រឹមត្រូវកើនឡើងពី ៦៤% ដល់៧៨%

លោកស្រី ជាលតាក់កឺ ប្រធានទីប្រឹក្សាបច្ចេកទេសនៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាបានថ្លែងថា ៖ `ពួកយើងត្រូវបានលើកទឹកចិត្ត តាមរយៈការធ្វើឲ្យប្រសើរឡើងរបស់រោងចក្រ២៩៨ទាំងនេះ ចាប់តាំងពីគម្រោងរបាយការណ៍តម្លាភាពបានបង្កើត។ បញ្ហាជាច្រើនដែលរោងចក្រមិនបានធ្វើការកែប្រែ អស់រយៈពេលជាច្រើនឆ្នាំ ប៉ុន្តែឥឡូវពួកគេបានធ្វើការកែលម្អ ដូចអ្វីដែលបានឃើញក្នុងលទ្ធផលរបាយការណ៍តម្លាភាពនេះ។´

`ពួកយើងនឹងបន្តធ្វើការជាមួយក្រសួងពាណិជ្ជកម្ម និងក្រសួងការងារលើដើមគំនិតនេះ ពិសេសដើម្បីធ្វើការផ្លាស់ប្តូររោងចក្រទាំងឡាយ ដែលស្ថិតក្នុងក្រុមអនុវត្តច្បាប់មានកម្រិតទាប។´

ការអនុវត្តច្បាប់របស់សហជីព ជាមួយនឹងតម្រូវការច្បាប់ក្នុងការធ្វើកូដកម្ម ក៏ត្រូវបានបង្ហាញផងដែរ។ គ្រប់កូដកម្មទាំងអស់ ដែលត្រូវបានរួមបញ្ចូលនៅក្នុងទិន្នន័យតម្លាភាព នៅខែតុលាឆ្នាំ២០១៤នេះ គ្មានកូដកម្មណាមួយ ដែលបានធ្វើឡើងនៅក្នុងរោងចក្រគោរពនីតិវិធី និងតម្រូវការរបស់ច្បាប់ទេ។ ពត៌មានលម្អិតអំពីរោងចក្រទាំងអស់ ក៏ដូចជាសហជីព ដែលមាននៅក្នុងរបាយការណ៍នេះ អាចរកតាមរយៈ http://betterfactories.org/transparency/។

របាយការណ៍តម្លាភាពសង្ខេបត្រូវបានភ្ជាប់ជូន។

សម្រាប់ពត៌មានលម្អិត សូមទាក់ទង៖
លោក លី សុខេហាង
ជំនួយការទំនាក់ទំនង
ទូរស័ព្ទលេខ៖ ០១៥ ៩៩៩ ២២៩
អ៊ីម៉ែល៖ ly@ilo.org

Better Factories Cambodia

International Labour Organization
#9, Street 322
Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642
Tel (+855) 23 212 847
(+855) 23 220 362